神奈川県

KANAGAWA

# សេចក្តីណែនាំអំពីការ លើកកម្ពស់គោលនយោបាយ អន្តរជាតិកាណាហ្គាវ៉ា

## ខ្លឹមសារសង្ខេប

បោះពុម្ពលើកទី៥

សម្រេចបាននូវសង្គមរួមរស់ពហុវប្បធម៌ប្រកបដោយសន្តិភាព តាមរយៈកិច្ចសហប្រតិបត្តិការ និងកិច្ចសហការទូលំទូលាយ ពង្រីកយុទ្ធសាស្ត្រសកលដែលប្រើភាពខ្លាំងនៃខេត្តកាណាហ្គាវ៉ា

រដ្ឋបាលខេត្តកាណាហ្គាវ៉ា

ការិយាល័យកិច្ចការអន្តរជាតិផ្នែកវប្បធម៌ កីឡា និងទេសចរណ៍

1 Nihonodori, Naka, Yokohama, Kanagawa 231-8588

ទូរសព្ទ (045)210-3748 (ផ្ទាល់)

ទូរសារ (045)212-2753

CLAIR

一般財団法人

自治体国際化協会

ខិត្តប័ណ្ណនេះត្រូវបានបង្កើតឡើង ដោយមានការគាំទ្រពី សមាគមសម្រាប់ រដ្ឋបាលតំបន់ និងទំនាក់ទំនងអន្តរជាតិ

# 1 គោលបំណងនៃសេចក្ដីណែនាំ និងគោលបំណងនៃការកែសម្រួល

សេចក្ដីណែនាំនេះមានគោលបំណងដើម្បីប្រជាជនខេត្តអាចរស់នៅប្រកបដោយទឹកចិត្តទូលំទូលាយ រីករាយនិងគុណតម្លៃ ដោយមិនគិតពីសញ្ជាតិ ស្របពេលដែលសង្គម និងសេដ្ឋកិច្ចឈានទៅសកលភាវូបនីយកម្ម និងគ្មានព្រំដែនយ៉ាងឆាប់រហ័ស ហើយទំនាក់ទំនងអន្តរជាតិរវាងប្រទេស តំបន់ និងប្រជាជនកាន់តែស៊ីជម្រៅ។ ឯកសារនេះបង្ហាញពីវិធីសាស្ត្រ និងទិសដៅសម្រាប់ការអភិវឌ្ឍគោលនយោបាយអន្តរជាតិរបស់ខេត្តតាមទស្សនៈរបស់អ្នកពាក់ព័ន្ធ។
ខេត្តបានបង្កើត "ផែនការលើកកម្ពស់គោលនយោបាយអន្តរជាតិកាណាហ្គាវ៉ា" នៅខែឧសភាឆ្នាំ1991 ដើម្បីអនុវត្តគោលនយោបាយអន្តរជាតិជាប្រព័ន្ធ។ ចាប់តាំងពីពេលនោះមក ខេត្តបានធ្វើកំណែទម្រង់ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្ដូរក្នុងបរិយាកាសអន្តរជាតិ ខណៈខិតខំធ្វើការលើគោលនយោបាយផ្សេងៗជាច្រើន។

7ឆ្នាំបានកន្លងផុត ចាប់តាំងពីសេចក្ដីណែនាំបច្ចុប្បន្នត្រូវបានកែសម្រួលហើយចំនួនជនបរទេសដែលរស់នៅក្នុងខេត្តកំពុងកើនឡើងបន្ថែមទៀត។ វាក៏ចាំបាច់ផងដែរ ដើម្បីឆ្លើយតបទៅនឹងនិន្នាការជាតិ ដូចជាវឌ្ឍនភាពក្នុងការទទួលយកធនធានមនុស្សពីបរទេស តាមរយៈការបង្កើតប្រព័ន្ធជំនាញជាក់លាក់ ការលើកកម្ពស់គោលនយោបាយរួមរស់ពហុវប្បធម៌ដោយផ្អែកលើចំណុចនេះនិងការលើកកម្ពស់ការអប់រំភាសាជប៉ុនជាដើម។
លើសពីនេះ យើងត្រូវឈានទៅមុខដោយមានការគាំទ្រចំពោះបញ្ហាដែលបានកើតឡើងជាផលប៉ះពាល់ពីការរាតត្បាតនៃមេរោគកូវីដ។ ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្ដូរក្នុងស្ថានភាពដូចនេះ យើងនឹងកែសម្រួលសេចក្ដីណែនាំស្ដីពីការលើកកម្ពស់គោលនយោបាយអន្តរជាតិកាណាហ្គាវ៉ាដើម្បីលើកកម្ពស់បន្ថែមទៀតនូវគំនិតផ្ដួចផ្ដើមនៃគោលនយោបាយអន្តរជាតិនៃខេត្តនេះ។

# 2 ស្ថានភាពជនបរទេសដែលរស់នៅក្នុងខេត្ត

គិតត្រឹមខែមករាឆ្នាំ2023 មានជនបរទេសចំនួន 239,301នាក់រស់នៅក្នុងខេត្ត ហើយចំនួនប្រទេស និងតំបន់គឺ176 ដែលជាចំនួនខ្ពស់បំផុតមិនធ្លាប់មាន ហើយខេត្តនេះកាន់តែមានភាពចម្រុះ។ តាមប្រទេស/តំបន់ ប្រទេសចិនមានចំនួន29.4% នៃចំនួនសរុប បន្ទាប់មកគឺ វៀតណាម កូរ៉េខាងត្បូង ហ្វីលីពីន និងនេប៉ាល់។

ចំនួនជនបរទេសដែលរស់នៅក្នុងខេត្តដែលមានស្ថានភាពស្នាក់នៅ ដូចជាអ្នករស់នៅអចិន្ត្រៃយ៍ ឬអ្នកស្នាក់នៅរយៈពេលវែង មាន139,029នាក់ក្នុងឆ្នាំ2022 ស្មើនឹង1.2ដង បើធៀបនឹង 113,746នាក់ក្នុងឆ្នាំ2012។

រូប1 ចំនួនជនបរទេសនៅក្នុងខេត្ត និងចំនួនជនបរទេសដែលស្នាក់នៅរយៈពេលវែង




រៀបចំដោយការិយាល័យអន្តរជាតិនៃខេត្ត ផ្អែកលើស្ថិតិជនបរទេសនៅក្នុងខេត្ត(ខេត្តកាណាហ្គាវ៉ា) និងស្ថិតិជនបរទេសដែលស្នាក់នៅ(អគ្គនាយកដ្ឋានអន្តោប្រវេសន៍)

ចំណាំ1) ចំនួនជនបរទេសគឺជាចំនួនជនបរទេសដែលបានចុះបញ្ជីដោយផ្អែកលើច្បាប់ចុះបញ្ជីជនបរទេសរហូតដល់ឆ្នាំ2011 និងចំនួនជនបរទេសដែលមានក្នុងបញ្ជីស្នាក់នៅគោលចាប់ពីឆ្នាំ 2012មក(ទិន្នន័យរហូតដល់ឆ្នាំ2012 គឺគិតត្រឹមថ្ងៃ31ខែធ្នូ ហើយទិន្នន័យចាប់ពីឆ្នាំ2013មក គឺគិតត្រឹមថ្ងៃ1ខែមករា)

ចំណាំ2) ទាក់ទងនឹងចំនួនជនបរទេសស្នាក់នៅរយៈពេលវែង គឺជាជនបរទេសតាមស្ថានភាពស្នាក់នៅ(ចំនួនសរុប)នៃ"ស្ថិតិជនបរទេសស្នាក់នៅ(អគ្គនាយកដ្ឋានអន្តោប្រវេសន៍)" ដែលជាចំនួនសរុបនៃអ្នកដែលមានស្ថានភាពស្នាក់នៅ ដូចជា អ្នករស់នៅអចិន្ត្រៃយ៍ ប្ដីឬប្រពន្ធសញ្ជាតិជប៉ុន ប្ដីឬប្រពន្ធនៃអ្នករស់នៅអចិន្ត្រៃយ៍ អ្នកស្នាក់នៅរយៈពេលវែង អ្នករស់នៅអចិន្ត្រៃយ៍ពិសេស។

# 3 ស្ថានភាពកុមារដែលមានទំនាក់ទំនងជាមួយបរទេស (*)

ចំនួនកុមារបរទេសដែលបានចូលរៀននៅសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យក្នុងខេត្តបានកើនឡើងប្រមាណ1.8ដង ពី7,060នាក់ក្នុងឆ្នាំ2012 ដល់12,725នាក់ក្នុងឆ្នាំ2023។

### រូប2 ចំនួនកុមារបរទេសដែលបានចូលរៀននៅសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យក្នុងខេត្ត




រៀបចំដោយការិយាល័យអន្តរជាតិនៃខេត្ត ផ្អែកលើការសិក្សាមូលដ្ឋានលើសាលារៀនក្នុងខេត្តកាណាហ្គាវ៉ា

*កុមារដែលមានទំនាក់ទំនងជាមួយបរទេស៖ សំដៅដល់មិនត្រឹមតែកុមារដែលមានសញ្ជាតិបរទេសទេ ថែមទាំង "កុមារដែលភាសាកំណើតមិនមែនជាភាសាជប៉ុន ទោះពួកគេមានសញ្ជាតិជប៉ុន" និង "កុមារដែលមានគ្រួសារមានឫសគល់នៅបរទេស" ក៏ដូចជាកុមារដែលមានសាវតាផ្សេងៗដូចជាជាតិសាសន៍ និងវប្បធម៌ផ្សេងៗ។

# 4 ស្ថានភាពនិស្សិតបរទេស

ចំនួននិស្សិតបរទេសក្នុងខេត្តបានកើនឡើងជារៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ2013 ហើយនៅឆ្នាំ2019 បានឈានដល់កម្រិតខ្ពស់បំផុតគឺ13,855នាក់។ ចាប់តាំងពីឆ្នាំ2020 ចំនួនបានថយចុះតាមរយៈការរឹតត្បិតចូលប្រទេសជប៉ុន ដោយសារការឆ្លងមេរោគកូរ៉ូណាប្រភេទថ្មី ប៉ុន្តែវាបានកើនឡើងម្តងទៀតនៅឆ្នាំ2023។

### រូប3 ចំនួននិស្សិតបរទេសក្នុងខេត្ត




ការសិក្សាលើនិស្សិតបរទេសនៅតាមសាកលវិទ្យាល័យជាដើមក្នុងខេត្តកាណាហ្គាវ៉ា(ខេត្តកាណាហ្គាវ៉ា)

# គោលដៅមូលដ្ឋាន និងទិសដៅនៃគោលនយោបាយ

## គោលបំណង

- សម្រេចបាននូវសង្គមរួមរស់ពហុវប្បធម៌ប្រកបដោយសន្តិភាព តាមរយៈកិច្ចសហប្រតិបត្តិការ និងកិច្ចសហការទូលំទូលាយ
- ពង្រីកយុទ្ធសាស្ត្រសកលដែលប្រើភាពខ្លាំងនៃខេត្តកាណាហ្គាវ៉ា

## គោលដៅមូលដ្ឋាន

1. បង្កើតសហគមន៍ពហុវប្បធម៌
2. ពង្រីកអន្តរជាតិដែលប្រើ ភាពខ្លាំងនៃខេត្តកាណាហ្គាវ៉ា
3. លើកកម្ពស់សកម្មភាពនៃធនធានមនុស្សសកល។ល។
4. ផ្សព្វផ្សាយការយល់ដឹងអំពីសន្តិភាព និងមិនមែននុយក្លេអ៊ែរ
5. គាំទ្រសកម្មភាពអន្តរជាតិរបស់ប្រជាជនខេត្ត និងលើកកម្ពស់កិច្ចសហប្រតិបត្តិការ និងកិច្ចសហការ

## ទិសដៅនៃគោលនយោបាយ

**1** (បង្កើតសហគមន៍ពហុវប្បធម៌)
- (1) បង្កើតបរិយាកាសងាយស្រួលជនបរទេសរស់នៅ
- (2) លើកកម្ពស់ការអប់រំភាសាជប៉ុន
- (3) ជួយដល់កុមារដែលមានទំនាក់ទំនងជាមួយបរទេស
- (4) ជួយដល់ និស្សិតអន្តរជាតិដែលរស់នៅ និងសិក្សានៅកាណាហ្គាវ៉ា
- (5) ជួយដល់ ជនបរទេសរស់នៅក្នុងខេត្តក្នុងពេលមានគ្រោះមហន្តរាយ ។ល។
- (6) លើកកម្ពស់ការយល់ដឹងពហុវប្បធម៌

**2** (ពង្រីកអន្តរជាតិដែលប្រើ ភាពខ្លាំងនៃខេត្តកាណាហ្គាវ៉ា)
- (7) គាំទ្រការពង្រីកទៅក្រៅប្រទេសនៃក្រុមហ៊ុនខេត្តនិងទាក់ទាញក្រុមហ៊ុនបរទេស
- (8) លើកកម្ពស់ និងផ្សព្វផ្សាយ "ព្រំដែនថ្មីនៃការថែទាំសុខភាព"
- (9) ផ្សព្វផ្សាយទាក់ទាញទេសចរបរទេស
- (10) លើកកម្ពស់ "Magcul"

**3** (លើកកម្ពស់សកម្មភាពនៃធនធានមនុស្សសកល។ល។)
- (11) លើកកម្ពស់ការផ្លាស់ប្តូរ និងកិច្ចសហប្រតិបត្តិការអន្តរជាតិដែលទាញយកអត្ថប្រយោជន៍ពីខេត្ត
- (12) អភិវឌ្ឍធនធានមនុស្សដែលអាចដើរតួនាទីសកម្មក្នុងសង្គមអន្តរជាតិ
- (13) លើកកម្ពស់សកម្មភាពនៃធនធានមនុស្សបរទេស
- (14) បង្កើតបរិស្ថានដែលធនធានបរទេសងាយស្រួលធ្វើការ

**4** (ផ្សព្វផ្សាយការយល់ដឹងអំពីសន្តិភាព និងមិនមែននុយក្លេអ៊ែរ)
- (15) ផ្សព្វផ្សាយការយល់ដឹងអំពីសន្តិភាព និងមិនមែននុយក្លេអ៊ែរ

**5** (គាំទ្រសកម្មភាពអន្តរជាតិរបស់ប្រជាជនខេត្ត និងលើកកម្ពស់កិច្ចសហប្រតិបត្តិការ និងកិច្ចសហការ)
- (16) គាំទ្រ សហ ប្រតិបត្តិការ និងសហការដល់ សកម្មភាពប្រជាជនខេត្ត
- (17) លើកកម្ពស់វិធានការចំពោះមូលដ្ឋានយោធា
- (18) ទប់ស្កាត់បញ្ហាចាប់ជំរិត និងលើកកម្ពស់ការយល់ដឹងរបស់ប្រជាជនខេត្ត

# ទិសដៅនៃគោលនយោបាយ

# គោលដៅមូលដ្ឋាន 1 បង្កើតសហគមន៍ ពហុវប្បធម៌

## (1) បង្កើតបរិយាកាសងាយស្រួលជនបរទេសរស់នៅ

ដើម្បីបង្កើតបរិស្ថានដែលជនបរទេសអាចរស់នៅប្រកបដោយភាពរស់រវើកក្នុងសហគមន៍ យើងនឹងពង្រីកប្រព័ន្ធប្រឹក្សាពិគ្រោះទូទៅសម្រាប់ជនបរទេស ផ្តល់ព័ត៌មានជាច្រើនភាសា និងជាភាសាជប៉ុនងាយស្រួល ព្រមទាំងលើកកម្ពស់គោលនយោបាយក្នុងវិស័យផ្សេងៗទាក់ទងនឹងជីវិតប្រចាំថ្ងៃ ដូចជាការបញ្ជូនអ្នកបកប្រែទៅកាន់ស្ថាប័នវេជ្ជសាស្ត្រ និងស្ថាប័នសាធារណៈ និងជំនួយសម្រាប់ការចូលមកស្នាក់នៅ។
លើសពីនេះ នៅក្នុងកិច្ចខិតខំប្រឹងប្រែងទាំងនេះ យើងនឹងធ្វើការរួមគ្នាជាមួយជនបរទេសដែលរស់នៅក្នុងខេត្ត និងលើកទឹកចិត្តឱ្យមានការចូលរួមក្នុងការកសាងសហគមន៍។ យើងក៏នឹងធ្វើការដើម្បីលើកកម្ពស់គោលនយោបាយសិទ្ធិមនុស្ស រួមទាំងការកែលម្អច្បាប់ និងប្រព័ន្ធទាក់ទងនឹងជនបរទេស និងការលុបបំបាត់ការនិយាយស្អប់ខ្ពើម។

**[ការអភិវឌ្ឍគោលនយោបាយ]**

- លើកកម្ពស់ប្រព័ន្ធប្រឹក្សាពិគ្រោះ និងផ្តល់ព័ត៌មានសម្រាប់ជនបរទេស។ល។
- លើកកម្ពស់ការគាំទ្រជីវភាពរស់នៅប្រចាំថ្ងៃរបស់ជនបរទេស។ល។
- លើកកម្ពស់សេវាវេជ្ជសាស្ត្រ និងសុខុមាលភាពដល់ជនបរទេស។ល។
- លើកកម្ពស់ការបណ្តុះបណ្តាលអ្នកគាំទ្រសំដៅដោះស្រាយបញ្ហាប្រឈមរបស់ជនបរទេស។ល។
- លើកកម្ពស់ការចូលរួមរបស់ជនបរទេសក្នុងរដ្ឋបាលតំបន់
- គោរពសិទ្ធិមនុស្សរបស់ជនបរទេស។ល។
- កែលម្អច្បាប់ និងប្រព័ន្ធទាក់ទងនឹងជនបរទេស

## (2) លើកកម្ពស់ការអប់រំភាសាជប៉ុន

ដើម្បីបង្កើតបរិស្ថានដែលជនបរទេសអាចរស់នៅ និងដើរតួនាទីសកម្មជាសមាជិកនៃសហគមន៍ ដោយទំនុកចិត្ត នៅតាមតំបន់នីមួយៗនៃខេត្ត យើងផ្តល់ការគាំទ្រសមស្របតាមភាពជាក់ស្តែងនៃសហគមន៍ ដើម្បីឱ្យជនបរទេស អាចទទួលបានសមត្ថភាពភាសាជប៉ុនចាំបាច់ ក៏ដូចជាការអប់រំភាសាជប៉ុនសម្រាប់កុមារដែលមានទំនាក់ទំនងជាមួយបរទេស និងពលករបរទេស។

**[ការអភិវឌ្ឍគោលនយោបាយ]**

- រៀបចំប្រព័ន្ធអប់រំភាសាជប៉ុនតាមតំបន់ ដោយសហការជាមួយខណ្ឌសង្កាត់ភូមិ និងស្ថាប័នពាក់ព័ន្ធ
- បណ្តុះបណ្តាលធនធានមនុស្ស និងកសាងបណ្តាញដើម្បីគាំទ្រដល់សកម្មភាពអប់រំភាសាជប៉ុនក្នុងសហគមន៍
- លើកកម្ពស់ការផ្តល់ព័ត៌មានទាក់ទងនឹងការអប់រំភាសាជប៉ុនក្នុងសហគមន៍ និងលើកកម្ពស់លទ្ធភាពទទួលបានការសិក្សាភាសាជប៉ុនសម្រាប់ជនបរទេស។ល។
- លើកកម្ពស់ការអប់រំភាសាជប៉ុនសម្រាប់កុមារដែលមានទំនាក់ទំនងជាមួយបរទេស
- លើកកម្ពស់ការអប់រំភាសាជប៉ុនដល់ពលករបរទេស។ល។



[វគ្គសិក្សាភាសាជប៉ុនសម្រាប់អ្នកចាប់ផ្តើមដំបូង]



[វគ្គបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តភាសាជប៉ុន សហការជាមួយខណ្ឌសង្កាត់ភូមិ]

# ទិសដៅនៃគោលនយោបាយ

# គោលដៅមូលដ្ឋាន 1 បង្កើតសហគមន៍ ពហុវប្បធម៌

## (3) ជួយដល់កុមារដែលមានទំនាក់ទំនងជាមួយបរទេស

ដើម្បីបង្កើតបរិស្ថានដែលកុមារដែលមានទំនាក់ទំនងជាមួយបរទេសអាចលូតលាស់ និងរៀនដោយទំនុកចិត្ត យើងធ្វើការសហការជាមួយខណ្ឌសង្កាត់ភូមិនិងអង្គភាពពាក់ព័ន្ធនានាដើម្បីផ្តល់ការគាំទ្រដល់កុមារដែលមានទំនាក់ទំនងជាមួយបរទេស ដូចជាការពង្រីកឱកាសសិក្សា និងជំនួយពហុភាសាក្នុងការចិញ្ចឹមអប់រំកូន ។

**[ការអភិវឌ្ឍគោលនយោបាយ]**

- ពង្រីកឱកាសសិក្សាដល់កុមារដែលមានទំនាក់ទំនងជាមួយបរទេស
- ពង្រឹងការអប់រំដល់កុមារដែលមានទំនាក់ទំនងជាមួយបរទេស
- លើកកម្ពស់ការបណ្តុះបណ្តាលគ្រូនិងអ្នកគាំទ្រ។ល។
- លើកកម្ពស់ការគាំទ្រដល់ការចិញ្ចឹមអប់រំកូនចំពោះជនបរទេសរស់នៅក្នុងខេត្ត។ល។

## (4) ជួយដល់ និស្សិតអន្តរជាតិដែលរស់នៅ និងសិក្សានៅកាណាហ្គាវ៉ា

បន្ថែមពីលើប្រតិបត្តិការ "ក្លឹបអ្នកគាំទ្រអន្តរជាតិកាណាហ្គាវ៉ា KANAFAN STATION" ដែលផ្តល់ការប្រឹក្សាពិគ្រោះទាក់ទងជីវិតនិងការងារ និងជាកន្លែងសម្រាប់ផ្លាស់ប្តូរនិស្សិតអន្តរជាតិដែលកំពុងរស់នៅ និងសិក្សាក្នុងកាណាហ្គាវ៉ា យើងក៏ផ្តល់ការគាំទ្រដោយសហការជាមួយស្ថាប័នអប់រំ ដូចជាសាកលវិទ្យាល័យ និងសាលាវិជ្ជាជីវៈ NPO និងក្រុមហ៊ុន ក៏ដូចជាការគាំទ្រសម្រាប់ការស្វែងរកការងារធ្វើនៅក្នុងខេត្ត និងបន្តខិតខំផ្សាភ្ជាប់និស្សិតអន្តរជាតិជាមួយសហគមន៍។

**[ការអភិវឌ្ឍគោលនយោបាយ]**

- ពង្រីកការគាំទ្រនិស្សិតអន្តរជាតិដែលផ្តោតលើ "ក្លឹបអ្នកគាំទ្រអន្តរជាតិកាណាហ្គាវ៉ា KANAFAN STATION"
- គាំទ្រដល់និស្សិតអន្តរជាតិ ដោយសហការជាមួយស្ថាប័នអប់រំ NPO ក្រុមហ៊ុន។ល។
- ជំនួយស្វែងរកការងារនៅក្នុងខេត្តក្រោយបញ្ចប់ការសិក្សា




[ព្រឹត្តិការណ៍ផ្លាស់ប្តូរវប្បធម៌ក្នុងក្លឹបអ្នកគាំទ្រអន្តរជាតិកាណាហ្គាវ៉ា KANAFAN STATION]



[ស្ថានភាពនៅ KANAFAN STATION]

# ទិសដៅនៃគោលនយោបាយ

# គោលដៅមូលដ្ឋាន 1 បង្កើតសហគមន៍ ពហុវប្បធម៌

## (5) ជួយដល់ជនបរទេសរស់នៅក្នុងខេត្ត ក្នុងពេលមានគ្រោះមហន្តរាយ។ល។

យើងធ្វើការសហការជាមួយខណ្ឌសង្កាត់ភូមិ និងស្ថាប័នពាក់ព័ន្ធ ដើម្បីផ្តល់ការគាំទ្រដល់ជនបរទេស រួមទាំងការផ្តល់ព័ត៌មានជាច្រើនភាសា និងជាភាសាជប៉ុនសាមញ្ញ ក្នុងគ្រាមានគ្រោះមហន្តរាយ ឬការរីករាលដាលនៃជំងឺឆ្លង។

**[ការអភិវឌ្ឍគោលនយោបាយ]**

- លើកកម្ពស់ការប្រឹក្សាពិគ្រោះ និងការផ្តល់ព័ត៌មានដល់ជនបរទេស ក្នុងគ្រាមានគ្រោះមហន្តរាយ។ល។
- បណ្តុះបណ្តាលដល់អ្នកស្ម័គ្រចិត្តបកប្រែពេលមានគ្រោះមហន្តរាយ

## (6) លើកកម្ពស់ការយល់ដឹងពហុវប្បធម៌

ដើម្បីលើកកម្ពស់ការយល់ដឹងពីពហុវប្បធម៌ យើងផ្តល់ឱកាសសិក្សា និងព័ត៌មាននៅក្នុងសហគមន៍ ហើយថែមទាំងរៀបចំព្រឹត្តិការណ៍ក្រោមប្រធានបទការរួមរស់ពហុវប្បធម៌ផងដែរ។ លើសពីនេះ យើង បើកការបណ្តុះបណ្តាលឱ្យកាន់តែស៊ីជម្រៅអំពីពហុវប្បធម៌នៅសាលារៀនជាដើម ក៏ដូចជាការបណ្តុះបណ្តាលសម្រាប់អ្នកដែលគាំទ្រជនបរទេសជាដើម និងសិក្ខាសាលាសម្រាប់ប្រជាជនខេត្ត។

**[ការអភិវឌ្ឍគោលនយោបាយ]**

- លើកកម្ពស់ការយល់ដឹងពហុវប្បធម៌ក្នុងសហគមន៍
- លើកកម្ពស់ការយល់ដឹងពហុវប្បធម៌ក្នុងការអប់រំនៅសាលា
- អនុវត្ត និងពង្រីកវគ្គសិក្សា និងការបណ្តុះបណ្តាល ដើម្បីឱ្យកាន់តែស៊ីជម្រៅនូវការយល់ដឹងពហុវប្បធម៌



[Earth Festa Kanagawa]



[បណ្ណាល័យពិភពលោករបស់ Kanagawa Plaza for Global Citizenship (Earth Plaza)]

# ទិសដៅនៃគោលនយោបាយ

# គោលដៅមូលដ្ឋាន 2 ពង្រីកអន្តរជាតិដែលប្រើ ភាពខ្លាំងនៃខេត្តកាណាហ្គាវ៉ា

## (7) គាំទ្រការពង្រីកទៅក្រៅប្រទេសនៃក្រុមហ៊ុនខេត្ត និងទាក់ទាញក្រុមហ៊ុនបរទេស

ដើម្បីលើកទឹកចិត្តសហគ្រាសធុនតូចនិងមធ្យមដែលមានបច្ចេកវិទ្យាទំនើបដើម្បីពង្រីកបណ្តាញលក់នៅក្រៅប្រទេស យើងគាំទ្រការពង្រីកនៅក្រៅប្រទេសដោយផ្តល់ព័ត៌មានស្តីពីការពង្រីកអាជីវកម្មនៅក្រៅប្រទេស និងរៀបចំកិច្ចប្រជុំប្រឹក្សាពិគ្រោះ។ ម្យ៉ាងទៀត ដើម្បីទាក់ទាញក្រុមហ៊ុនបរទេស យើងធ្វើសកម្មភាពផ្សព្វផ្សាយនៅក្រៅប្រទេស និងគាំទ្រដល់ការចាប់ផ្តើមក្រុមហ៊ុនបរទេស។

**[ការអភិវឌ្ឍគោលនយោបាយ]**

- គាំទ្រដល់ការពង្រីកនៅក្រៅប្រទេសនៃសហគ្រាសធុនតូចនិងមធ្យម
- ទាក់ទាញក្រុមហ៊ុនបរទេសតាមរយៈការផ្សព្វផ្សាយនៅក្រៅប្រទេស។ល។



[សិក្ខាសាលាទាក់ទាញក្រុមហ៊ុននានា រៀបចំនៅទីក្រុងហាណូយ ប្រទេសវៀតណាម]



[កិច្ចប្រជុំធុរកិច្ចបានធ្វើឡើងនៅទីក្រុង Dalian ប្រទេសចិន]

## (8) លើកកម្ពស់ និងផ្សព្វផ្សាយ "ព្រំដែនថ្មីនៃការថែទាំសុខភាព"

តាមរយៈការសហការជាមួយតំបន់ក្រៅប្រទេសដែលជឿនលឿនផ្នែកឧស្សាហកម្មវិទ្យាសាស្រ្តជីវិត  និងអង្គការសុខភាពពិភពលោក យើងធ្វើការផ្សព្វផ្សាយនូវគោលគំនិត ME-BYO និង "Vibrant INOCHIឬសង្គមដែលជីវិតភ្លឺស្វាង" ព្រមទាំងលើកកម្ពស់ការពង្រីកអន្តរជាតិនូវការថែទាំវេជ្ជសាស្រ្តឈានមុខ និងឧស្សាហកម្មថែទាំមុនឈានដល់ជំងឺ ។

**[ការអភិវឌ្ឍគោលនយោបាយ]**

- លើកកម្ពស់ការពង្រីកអន្តរជាតិក្នុងការថែទាំវេជ្ជសាស្រ្តឈានមុខ និងឧស្សាហកម្មថែទាំមុនឈានដល់ជំងឺ ។ល។
- ផ្សព្វផ្សាយកិច្ចខិតខំលើគោលនយោបាយថែទាំសុខភាពតាមរយៈការសហការជាមួយអង្គការសុខភាពពិភពលោក (WHO)
- បណ្តុះបណ្តាលអ្នកជំនាញផ្នែកសុខភាពជំនាន់ក្រោយនៅ Graduate School of Health Innovation, សាកលវិទ្យាល័យសុខភាពសុខុមាលភាព

ទិសដៅនៃគោលនយោបាយ

# គោលដៅមូលដ្ឋាន 2 ពង្រីកអន្តរជាតិដែលប្រើ ភាពខ្លាំងនៃខេត្តកាណាហ្គាវ៉ា

## (9) ផ្សព្វផ្សាយទាក់ទាញទេសចរបរទេស

ស្វែងរក និងកែលម្អធនធានទេសចរណ៍ ដោយប្រើប្រាស់ទិន្នន័យទេសចរណ៍ពីភ្ញៀវទេសចរបរទេស ផ្សព្វផ្សាយព័ត៌មានទេសចរណ៍តាមរយៈគេហទំព័រជាដើម ព្រមទាំងអនុវត្តការផ្សព្វផ្សាយតាមរយៈតំណាងទេសចរណ៍ក្រៅប្រទេស (*)។ លើសពីនេះ ខិតខំកែលម្អបរិស្ថានដើម្បីទទួលភ្ញៀវទេសចរណ៍បរទេស ដូចជាបណ្តុះបណ្តាលមគ្គុទ្ទេសក៍ឯកទេសខ្ពស់ និងកែលម្អបរិស្ថាននៃគ្រឿងបរិក្ខារទាក់ទងនឹងទេសចរណ៍ ដើម្បីបង្កើនការពេញចិត្តរបស់ភ្ញៀវទេសចរបរទេស។

*តំណាងទេសចរណ៍៖ ជាប្រតិបត្តិករអាជីវកម្មដែលធ្វើការផ្សព្វផ្សាយលក់ក្នុងនាមរដ្ឋបាលតំបន់ ឬក្រុមហ៊ុនទៅកាន់ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក និងក្រុមហ៊ុនទេសចរណ៍ក្នុងស្រុក ក្នុងគោលបំណងនៃសកម្មភាពលក់ ការផ្តល់ព័ត៌មាន និងការផ្សព្វផ្សាយដើម្បីទាក់ទាញភ្ញៀវទេសចរបរទេស។

**[ការអភិវឌ្ឍគោលនយោបាយ]**

- ប្រើប្រាស់ទិន្នន័យទេសចរណ៍ ដូចជាការស្ទង់មតិលើតម្រូវការភ្ញៀវទេសចរបរទេស
- ស្វែងរក និងកែលម្អធនធានទេសចរណ៍ និងផ្សព្វផ្សាយព័ត៌មានទេសចរណ៍ តាមរយៈគេហទំព័រព័ត៌មានទេសចរណ៍ជាភាសាបរទេស។ល។
- អនុវត្តផ្សព្វផ្សាយដើម្បីទាក់ទាញភ្ញៀវទេសចរបរទេស
- អភិវឌ្ឍធនធានមនុស្សទេសចរណ៍ និងកែលម្អបរិស្ថានដើម្បីទទួលភ្ញៀវទេសចរបរទេស



[ការផ្សព្វផ្សាយផ្តោតលើក្រុមហ៊ុនទេសចរណ៍ក្រៅប្រទេស]



[កិច្ចប្រជុំធុរកិច្ចអនឡាញ MICE នៅតៃវ៉ាន់]

*MICE៖ កិច្ចប្រជុំរបស់ក្រុមហ៊ុន (Meeting), ការធ្វើដំណើរលើកទឹកចិត្តនិងបណ្តុះបណ្តាលដែលធ្វើឡើងដោយក្រុមហ៊ុន (Incentive Travel), សន្និបាតដែលធ្វើឡើងដោយអង្គការក្រុម សង្គមសិក្សាអន្តរជាតិ។ល។(Convention), ពិព័រណ៍ពាណិជ្ជកម្មឬព្រឹត្តិការណ៍អាជីវកម្មដែលរំពឹងថានឹងទាក់ទាញអតិថិជនយ៉ាងច្រើនទាក់ទងគ្នាទៅវិញទៅមក។

## (10) លើកកម្ពស់ "Magcul"

ផ្សព្វផ្សាយបន្ថែមទៀតនូវគំនិតផ្តួចផ្តើម Magnet Culture (Magcul) ដែលទាក់ទាញមនុស្សដែលដោយមនោស្នេហ៍នៃវប្បធម៌ និងសិល្បៈ និងបង្កើតភាពអ៊ូអរក្នុងតំបន់ ហើយផ្សព្វផ្សាយភាពទាក់ទាញនៃវប្បធម៌កាណាហ្គាវ៉ាទៅកាន់ពិភពលោក។

**[ការអភិវឌ្ឍគោលនយោបាយ]**

- ផ្សព្វផ្សាយព័ត៌មានច្រើនភាសានូវខ្លឹមសារដ៏ទាក់ទាញរបស់កាណាហ្គាវ៉ា

# ទិសដៅនៃគោលនយោបាយ

# គោលដៅមូលដ្ឋាន 3 លើកកម្ពស់សកម្មភាពនៃធនធានមនុស្សសកល។ល។

## (11) លើកកម្ពស់ការផ្លាស់ប្តូរ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដែលទាញយកអត្ថប្រយោជន៍ពីខេត្ត

លើកកម្ពស់ការផ្លាស់ប្តូរដែលផ្តោតលើដៃគូផ្លាស់ប្តូរមិត្តភាព និងកិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ ដូចជាគម្រោងផ្លាស់ប្តូរកីឡា និងវប្បធម៌ជាមួយយុវជនមកពីខេត្ត Liaoning ក្នុងប្រទេសចិន និងខេត្ត Gyeonggi ក្នុងប្រទេសកូរ៉េខាងត្បូង។ លើសពីនេះ ទទួលយក និងបណ្តុះបណ្តាលធនធានមនុស្សថ្នាក់កណ្តាល អ្នកដឹកនាំ និងសិក្ខាកាម ដើម្បីទទួលបានជំនាញ ដែលនឹងរួមចំណែកដល់ការអភិវឌ្ឍតំបន់កំពុងអភិវឌ្ឍន៍ និងតំបន់ផ្សេងៗទៀត ព្រមទាំងអភិវឌ្ឍធនធានមនុស្សផងដែរ។

**[ការអភិវឌ្ឍគោលនយោបាយ]**

- លើកកម្ពស់"ក្លឹបអ្នកគាំទ្រអន្តរជាតិកាណាហ្គាវ៉ា"ដែលមានគោលបំណងបង្កើតបណ្តាញជនបរទេសក្នុងនិងក្រៅប្រទេសជប៉ុន ដែលស្គាល់កាណាហ្គាវ៉ា ដូចជានិស្សិតអន្តរជាតិ។
- គាំទ្រដល់និស្សិតអន្តរជាតិ សហការជាមួយស្ថាប័នអប់រំ NPO ក្រុមហ៊ុន។ល។ [សរសេរឡើងវិញ]
- ជំរុញការផ្លាស់ប្តូរអន្តរជាតិជាមួយដៃគូផ្លាស់ប្តូរមិត្តភាព
- លើកកម្ពស់ការផ្លាស់ប្តូរអន្តរជាតិជាកេរ្តិ៍ដំណែលនៃកីឡាអូឡាំពិក និងប៉ារ៉ាឡាំពិកទីក្រុងតូក្យូឆ្នាំ2020
- ជំរុញការផ្លាស់ប្តូរអន្តរជាតិតាមរយៈការអញ្ជើញ និងរៀបចំសន្និសីទអន្តរជាតិ។ល។
- អភិវឌ្ឍធនធានមនុស្ស និងបញ្ជូនអ្នកដឹកនាំក្នុងវិស័យផ្សេងៗ
- សហការជាមួយអង្គការអន្តរជាតិក្នុងវិស័យបរិស្ថានពិភពលោក



[ស្ថានភាពក្នុងដំណើរទស្សនកិច្ចនៅខេត្ត Liaoning ប្រទេសចិន]



[ស្ថានភាពក្នុងដំណើរទស្សនកិច្ចរដ្ឋ Maryland សហរដ្ឋអាមេរិក]

## (12) អភិវឌ្ឍធនធានមនុស្សដែលអាចដើរតួនាទីសកម្មក្នុងសង្គមអន្តរជាតិ

តាមរយៈការអប់រំដែលឆ្លើយតបទៅនឹងអន្តរភាវូបនីយកម្ម និងការផ្តួចផ្តើមគំនិតនៅសាលាដែលទទួលស្គាល់បរិញ្ញាបត្រអន្តរជាតិ យើងបណ្តុះបណ្តាលធនធានមនុស្សដែលមានគំនិតសំបូរបែបលក្ខណៈអន្តរជាតិដែលអាចដើរតួយ៉ាងសកម្មនៅក្នុងសង្គមអន្តរជាតិ។ លើសពីនេះ យើងគាំទ្រសកម្មភាពផ្លាស់ប្តូរអន្តរជាតិ។

**[ការអភិវឌ្ឍគោលនយោបាយ]**

- លើកកម្ពស់ការអប់រំដែលឆ្លើយតបទៅនឹងអន្តរភាវូបនីយកម្ម
- ពង្រីកគំនិតផ្តួចផ្តើមនៅសាលាដែលទទួលស្គាល់បរិញ្ញាបត្រអន្តរជាតិ
- គាំទ្រការយល់ដឹងអន្តរជាតិ និងសកម្មភាពបទពិសោធន៍សម្រាប់យុវជន
- អនុវត្ត និងពង្រឹងការបណ្តុះបណ្តាលភាសាបរទេស។ល។
- លើកកម្ពស់ការសិក្សានៃពលរដ្ឋសកល(*)

*ពលរដ្ឋសកល៖ សំដៅលើមនុស្សដែលគិតក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេជាសមាជិកនៃផែនដី ហើយធ្វើសកម្មភាពក្បែរខ្លួនដែលខ្លួនអាចធ្វើ ដើម្បីដោះស្រាយបញ្ហាសកលដូចជាសន្តិភាព បរិស្ថាន សិទ្ធិមនុស្ស និងភាពក្រីក្រ។

## ទិសដៅនៃគោលនយោបាយ

## គោលដៅមូលដ្ឋាន 3 លើកកម្ពស់សកម្មភាពនៃធនធានមនុស្សសកល។ល។

### (13) លើកកម្ពស់សកម្មភាពនៃធនធានមនុស្សបរទេស

យើងរៀបចំការប្រជុំពន្យល់ពីក្រុមហ៊ុនរួមគ្នា និងវគ្គបណ្តុះបណ្តាលជំនួយការងារ ដើម្បីជួយនិស្សិតអន្តរជាតិស្វែងរក និងដោះស្រាយការងារនៅក្នុងខេត្ត ក៏ដូចជាក្រុមហ៊ុននានាក្នុងខេត្ត ក្នុងការទទួលយកជនបរទេស។ លើសពីនេះ យើងខិតខំក្នុងការរៀបចំប្រព័ន្ធគាំទ្រសម្រាប់គិលានុបដ្ឋាយិកាបរទេស និងបេក្ខជនបុគ្គលិកថែទាំសុខុមាលភាពដើម្បីទទួលបានគុណវុឌ្ឍិ។

**[ការអភិវឌ្ឍគោលនយោបាយ]**

- គាំទ្រដល់និស្សិតអន្តរជាតិ ក្នុងការស្វែងរកការងារនៅក្រុមហ៊ុននានាក្នុងខេត្ត
- លើកកម្ពស់ការគាំទ្រដល់គិលានុបដ្ឋាយិកាបរទេសនិងបេក្ខជនបុគ្គលិកថែទាំសុខុមាលភាពដើម្បីទទួលបានគុណវុឌ្ឍិ
- ទទួលយកនិស្សិតអន្តរជាតិនៅមណ្ឌលថែទាំ
- ទទួលនិស្សិតអន្តរជាតិនៅមហាវិទ្យាល័យបច្ចេកវិទ្យាឧស្សាហកម្មខេត្ត

### (14) បង្កើតបរិស្ថានដែលធនធានបរទេសងាយស្រួលធ្វើការ

ដើម្បីធានាថាបុគ្គលិកបរទេសអាចធ្វើការដោយទំនុកចិត្ត យើងនឹងពង្រឹង និងផ្តល់ការប្រឹក្សាពិគ្រោះការងារជាពហុភាសា ព្រមទាំងផ្តល់ការគាំទ្រ និងពង្រីកការយល់ដឹងអំពីបរិស្ថានការងារសមស្របដល់ក្រុមហ៊ុនដែលជួលបុគ្គលិកបរទេស។

**[ការអភិវឌ្ឍគោលនយោបាយ]**

- ប្រឹក្សាពិគ្រោះការងារជាពហុភាសា
- គាំទ្រ និងពង្រីកការយល់ដឹងដល់ក្រុមហ៊ុន។ល។

## ទិសដៅនៃគោលនយោបាយ

## គោលដៅមូលដ្ឋាន 4 ផ្សព្វផ្សាយការយល់ដឹងអំពីសន្តិភាព និងមិនមែននុយក្លេអ៊ែរ

### (15) ផ្សព្វផ្សាយការយល់ដឹងអំពីសន្តិភាព និងមិនមែននុយក្លេអ៊ែរ

ដើម្បីបង្កើតបរិយាកាសសន្តិភាព យើងនឹងបន្តយ៉ាងមុតមាំនូវភាពវិសេសនៃសន្តិភាព និងទុក្ខវេទនានៃសង្គ្រាមដល់មនុស្សជំនាន់ក្រោយ ព្រមទាំងផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងអំពីគោលបំណងនៃ "សេចក្តីប្រកាសតំបន់គ្មានអាវុធនុយក្លេអ៊ែរកាណាហ្គាវ៉ា" និងសហការជាមួយរដ្ឋបាលតំបន់ដែលបានប្រកាសថាគ្មានអាវុធនុយក្លេអ៊ែរនៅក្នុងខេត្ត។

**[ការអភិវឌ្ឍគោលនយោបាយ]**

- ផ្សព្វផ្សាយការយល់ដឹងអំពីសន្តិភាព និងគ្មានអាវុធនុយក្លេអ៊ែរ




[សេចក្តីប្រកាសខេត្តគ្មានអាវុធនុយក្លេអ៊ែរកាណាហ្គាវ៉ា]




[បន្ទប់តាំងពិពណ៌សន្តិភាពអន្តរជាតិនៅ Kanagawa Plaza for Global Citizenship (Earth Plaza)]

# ទិសដៅនៃគោលនយោបាយ

# គោលដៅមូលដ្ឋាន 5 គាំទ្រសកម្មភាពអន្តរជាតិរបស់ប្រជាជនខេត្ត និងលើកកម្ពស់កិច្ចសហប្រតិបត្តិការ និងកិច្ចសហការ

## (16) គាំទ្រ សហប្រតិបត្តិការ និងសហការដល់សកម្មភាពប្រជាជនខេត្ត

យើងលើកកម្ពស់កិច្ចសហការប្រតិបត្តិការ និងការសហការរវាងខេត្តជាមួយមូលនិធិអន្តរជាតិកាណាហ្គាវ៉ា NGO/NPO ខណ្ឌសង្កាត់ភូមិ ក្រុមហ៊ុន អង្គការពាក់ព័ន្ធ។ល។ ដើម្បីគាំទ្រ និងលើកកម្ពស់សកម្មភាពអន្តរជាតិរបស់ប្រជាជនខេត្ត និងដើម្បីធានាថាសកម្មភាពទាំងនេះបានអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព។

**[ការអភិវឌ្ឍគោលនយោបាយ]**

- គាំទ្រ និងលើកកម្ពស់សកម្មភាពអន្តរជាតិរបស់ប្រជាជនខេត្ត
- សហការជាមួយមូលនិធិអន្តរជាតិកាណាហ្គាវ៉ា(មូលនិធិសាធារណៈ)
- លើកកម្ពស់គោលនយោបាយអន្តរជាតិតាមរយៈកិច្ចសហការប្រតិបត្តិការ និងកិច្ចសហការ

## (17) លើកកម្ពស់វិធានការចំពោះមូលដ្ឋានយោធា

ខេត្តជំរុញការរៀបចំឡើងវិញ ការកាត់បន្ថយ និងការត្រឡប់មកវិញនៃមូលដ្ឋានយោធាសហរដ្ឋអាមេរិកនៅក្នុងខេត្ត ដោយសហការជាមួយរដ្ឋបាលតំបន់ដែលពាក់ព័ន្ធ។ លើសពីនេះ ដើម្បីធានា សុវត្ថិភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋនៅជិតមូលដ្ឋានយោធា និងបរិស្ថានរស់នៅល្អ យើងសហការជាមួយរដ្ឋបាលតំបន់ពាក់ព័ន្ធលើវិធានការជុំវិញមូលដ្ឋានយោធា។

**[ការអភិវឌ្ឍគោលនយោបាយ]**

- ជំរុញការរៀបចំ កាត់បន្ថយ និងត្រឡប់មកវិញនៃមូលដ្ឋានយោធា
- ពង្រឹងសុវត្ថិភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋនៅជិតមូលដ្ឋាន និងធានាបរិស្ថានរស់នៅល្អ
- ជំរុញកិច្ចសហការជាមួយមូលដ្ឋានយោធា

## (18) ទប់ស្កាត់បញ្ហាចាប់ជំរិត និងលើកកម្ពស់ការយល់ដឹងរបស់ប្រជាជនខេត្ត

ដោយផ្អែកលើ "ច្បាប់ស្តីពីការដោះស្រាយបញ្ហាចាប់ពង្រត់ និងបញ្ហារំលោភសិទ្ធិមនុស្សផ្សេងទៀតដោយអាជ្ញាធរកូរ៉េខាងជើង" (មាត្រា96ឆ្នាំ2006) យើងសហការជាមួយថ្នាក់ជាតិ ខណ្ឌសង្កាត់ភូមិ ក្រុមគាំទ្រ។ល។ ដើម្បីធ្វើការលើកកម្ពស់ការយល់ដឹងរបស់ប្រជាជនខេត្តអំពីបញ្ហាចាប់ពង្រត់។

**[ការអភិវឌ្ឍគោលនយោបាយ]**

- លើកកម្ពស់ការយល់ដឹងអំពីបញ្ហាចាប់ពង្រត់ រួមទាំងអ្នកដែលបាត់ខ្លួនជាពិសេស
- សហការជាមួយខណ្ឌសង្កាត់ភូមិ ក្រុមគាំទ្រ។ល។ លើបញ្ហាចាប់ពង្រត់
- លើកកម្ពស់ការអប់រំឱ្យកាន់តែស៊ីជម្រៅ និងការចាប់អារម្មណ៍លើបញ្ហាចាប់ពង្រត់
- ធ្វើការដើម្បីដោះស្រាយបញ្ហាចាប់ពង្រត់